ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

លេខ : ០០៣១/១៧ ក.អ.ជ

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រឡងជ្រើសរើសសិស្ស-និស្សិតឲ្យចូលបម្រើការងារ ជាមន្ត្រីរាជការក្នុងក្របខណ្ឌក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ឆ្នាំ ២០១៧

ក្រសួងអភិវឌ្ឍន៍ជនបទ មានកិត្តិយសសូមជូនដំណឹងដល់សិស្ស និស្សិតទាំង ០២ ភេទ ដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ និងវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនានា ឲ្យបានជ្រាបថា សម្រាប់ឆ្នាំ ២០១៧ នេះ ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវការជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី (ក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ "**ប្រភេទ ក**") <u>ចំនួន ៥១ រូប</u> ឲ្យចូលមកបម្រើការងារក្នុងក្របខណ្ឌក្រសួងអភិវឌ្ឍន៍ជនបទ (នៅទីស្តីការក្រសួង ចំនួន **២៧** រូប និងតាមមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ចំនួន **២៤** រូប)។

**១. លក្ខខណ្ឌជ្រើសរើស** ÷ បេក្ខជនទាំង ០២ ភេទ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ÷

១.១- មានសញ្ជាតិខ្មែរ

១.២- មានអាយុចន្លោះពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ(សម្រាប់បរិញ្ញាបត្រ) និង ៤០ឆ្នាំ សម្រាប់បរិញ្ញាបត្រជាន់ខ្ពស់)

១.៣- មានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ ។

**២. អង្គភាព និងសញ្ញាបត្រដែលត្រូវជ្រើសរើស**

ក. ទីស្តីការក្រសួង ÷ ត្រូវការជ្រើសរើសក្របខណ្ឌថ្មី <u>**ចំនួន ២៧ រូប**</u> រួមមាន ÷

| ល.រ | អង្គភាព | ចំនួនជ្រើសរើស | កម្រិតជំនាញ | ផ្សេងៗ |
|---|---|---|---|---|
| ១ | នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | ៥ | នីតិសាស្ត្រ ច្បាប់ រដ្ឋបាល រចនាប្ម័ន ភាសាអង់គ្លេស និងជំនាញពាក់ព័ន្ធ | |
| ២ | នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ | ៣ | គណនេយ្យ សេដ្ឋកិច្ច គ្រប់គ្រង រដ្ឋបាល និងជំនាញពាក់ព័ន្ធ | |
| ៣ | នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ | ២ | ផែនការ ព័ត៌មានវិទ្យា ទំនាក់ទំនងអន្តរជាតិ និងជំនាញពាក់ព័ន្ធ | |

| | | | | |
|---|---|---|---|---|
| ៤ | នាយកដ្ឋានបណ្ដុះបណ្ដាលនិងស្រាវជ្រាវ | ៣ | រដ្ឋបាល អភិវឌ្ឍន៍ធនធានមនុស្ស កសិកម្ម ភាសាអង់គ្លេស | |
| ៥ | នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច | ៤ | រដ្ឋបាល ផែនការ សេដ្ឋកិច្ច សង្គមវិទ្យា គណនេយ្យ សហគមន៍ អភិវឌ្ឍន៍ជនបទ ភាសាអង់គ្លេស និងជំនាញពាក់ព័ន្ធ | |
| ៦ | នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ | ១ | ទឹកក្រោមដី វិស្វកម្មសាស្ត្រ ធារាសាស្ត្រ ព័ត៌មានវិទ្យា | |
| ៧ | នាយកដ្ឋានថែទាំសុខភាពជនបទ | ២ | សុខភាពសាធារណៈ អភិវឌ្ឍន៍ជនបទ សហគមន៍បរិស្ថាន និងជំនាញពាក់ព័ន្ធ | |
| ៨ | នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ | ២ | អភិវឌ្ឍន៍ជនបទ សហគមន៍ កសិកម្ម និងជំនាញពាក់ព័ន្ធ | |
| ៩ | នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | ១ | សេដ្ឋកិច្ច ពាណិជ្ជកម្ម គណនេយ្យ ទីផ្សារ និងជំនាញពាក់ព័ន្ធ | |
| ១០ | នាយកដ្ឋានផ្លូវលំជនបទ | ៣ | វិស្វកម្មសាស្ត្រ ស្ថាបត្យកម្ម សំណង់ស៊ីវិល ធារាសាស្ត្រ បរិស្ថាន និងជំនាញពាក់ព័ន្ធ | |
| ១១ | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | ១ | នីតិសាស្ត្រ ច្បាប់ សវនកម្ម និងគណនេយ្យ | |

ខ. មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ៖ ត្រូវការជ្រើសរើសក្របខណ្ឌថ្មី ចំនួន ២៤ រូប ៖

| ល.រ | មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត | ចំនួនជ្រើសរើស | កម្រិតជំនាញ | ផ្សេងៗ |
|---|---|---|---|---|
| ១ | មន្ទីរខេត្តកំពត | ១ | អភិវឌ្ឍន៍ជនបទ សហគមន៍ និងជំនាញពាក់ព័ន្ធ | |
| ២ | មន្ទីរខេត្តកែប | ១ | អភិវឌ្ឍន៍ជនបទ សហគមន៍ និងជំនាញពាក់ព័ន្ធ | |
| ៣ | មន្ទីរខេត្តកោះកុង | ២ | អភិវឌ្ឍន៍ជនបទ សហគមន៍ និងជំនាញពាក់ព័ន្ធ | |
| ៤ | មន្ទីរខេត្តឧត្តរមានជ័យ | ១ | អភិវឌ្ឍន៍ជនបទ សហគមន៍ និងជំនាញពាក់ព័ន្ធ | |
| ៥ | មន្ទីរខេត្តប៉ៃលិន | ១ | អភិវឌ្ឍន៍ជនបទ សហគមន៍ និងជំនាញពាក់ព័ន្ធ | |
| ៦ | មន្ទីរខេត្តព្រះវិហារ | ២ | អភិវឌ្ឍន៍ជនបទ សហគមន៍ | |

| | | | | |
|---|---|---|---|---|
| | | | និងជំនាញពាក់ព័ន្ធ | |
| ៧ | មន្ទីរខេត្តកំពង់ធំ | ១ | អភិវឌ្ឍន៍ជនបទ សហគមន៍ និងជំនាញពាក់ព័ន្ធ | |
| ៨ | មន្ទីរខេត្តក្រចេះ | ១ | អភិវឌ្ឍន៍ជនបទ សហគមន៍ និងជំនាញពាក់ព័ន្ធ | |
| ៩ | មន្ទីរខេត្តរតនគិរី | ២ | អភិវឌ្ឍន៍ជនបទ សហគមន៍ និងជំនាញពាក់ព័ន្ធ | |
| ១០ | មន្ទីរខេត្តមណ្ឌលគិរី | ២ | អភិវឌ្ឍន៍ជនបទ សហគមន៍ និងជំនាញពាក់ព័ន្ធ | |
| ១១ | មន្ទីរខេត្តស្ទឹងត្រែង | ២ | អភិវឌ្ឍន៍ជនបទ សហគមន៍ និងជំនាញពាក់ព័ន្ធ | |
| ១២ | មន្ទីរខេត្តស្វាយរៀង | ៤ | អភិវឌ្ឍន៍ជនបទ សហគមន៍ និងជំនាញពាក់ព័ន្ធ | |
| ១៣ | មន្ទីរខេត្តកំពង់ឆ្នាំង | ៤ | អភិវឌ្ឍន៍ជនបទ សហគមន៍ និងជំនាញពាក់ព័ន្ធ | |

**៣. វិញ្ញាសាប្រឡងរួមមាន** ÷ វិញ្ញាសាសរសេរ និងវិញ្ញាសាផ្ទាល់មាត់÷

៣.១. វិញ្ញាសាសរសេរ ÷

- វិញ្ញាសាវប្បធម៌ទូទៅ (រយៈពេល ០២ម៉ោង ចាប់ពីម៉ោង ៧:០០នាទី ដល់ម៉ោង ៩:០០នាទី)
- វិញ្ញាសាជំនាញបច្ចេកទេស (រយៈពេល ០២ម៉ោង ចាប់ពីម៉ោង ៩:៣០នាទី ដល់ម៉ោង ១១:៣០នាទី)

៣.២. វិញ្ញាសាផ្ទាល់មាត់ ÷ សម្រាប់បេក្ខជនដែលប្រឡងជាប់វិញ្ញាសាសរសេរ ។

**៤. កាលបរិច្ឆេទប្រឡង**

- វិញ្ញាសាសរសេរ **នៅថ្ងៃ ទី ៣០ ខែមេសា ឆ្នាំ ២០១៧**
- វិញ្ញាសាផ្ទាល់មាត់ នឹងជូនដំណឹងនៅពេលក្រោយ ។

**៥. មណ្ឌលប្រឡង**

- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (វិញ្ញាសាសរសេរ)
- ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ (វិញ្ញាសាផ្ទាល់មាត់) ។

**៦. ទីកន្លែង កាលបរិច្ឆេទនៃការទទួលពាក្យ និងឈប់ទទួលពាក្យ**

៦.១. កាលបរិច្ឆេទទទួលពាក្យ ÷ ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ រៀងរាល់ម៉ោងធ្វើការងារ ពេលព្រឹកចាប់ពីម៉ោង ០៧:៣០ - ១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:៣០ - ១៧:០០ នាទី ។

៦.២. កាលបរិច្ឆេទឈប់ទទួលពាក្យ ÷ **ថ្ងៃសុក្រទី ០៧ ខែមេសា ឆ្នាំ ២០១៧ វេលាម៉ោង ១៧:០០ នាទី** ។

៦.៣. ទីកន្លែងទំនាក់ទំនង ទទួលពាក្យ និងដាក់ពាក្យ ÷ នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក (ជាន់ផ្ទាល់ដី) ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ កាច់ជ្រុងវិថីលេខ ១៦៩ និងមហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់មិត្តភាព ខណ្ឌ ៧មករា រាជធានីភ្នំពេញ ។

**៧. បេក្ខជនត្រូវបំពេញសំណុំលិខិតគ្រប់គ្រងការដាក់ពាក្យប្រឡង រួមមាន ÷**

៧.១. ពាក្យសុំចុះឈ្មោះប្រឡង........................................................ចំនួន ០១ ច្បាប់

៧.២. សេចក្តីចម្លងសញ្ញាបត្រដោយមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច.......ចំនួន ០១ ច្បាប់

៧.៣. ជីវប្រវត្តិសង្ខេបមានបិទរូបថត (៤ គុណ ៦)................................ចំនួន ០២ ច្បាប់

៧.៤. សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត.......ចំនួន ០១ ច្បាប់

៧.៥. សលាកបត្រឯកត្តជន..........................................................ចំនួន ០៣ ច្បាប់

៧.៦. កិច្ចសន្យាបម្រើការងារក្រសួង...................................................ចំនួន ០៣ ច្បាប់

៧.៧. បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង...............................................ចំនួន ០២ ច្បាប់

៧.៨. រូបថតថ្មី (៤ គុណ ៦) ថតចំពីមុខ................................................ចំនួន ០២ សន្លឹក

**បញ្ជាក់ ÷**

- បេក្ខជន ជាជនពិការ និងស្ត្រី ដែលមានសមត្ថភាពសមស្រប ត្រូវបានផ្តល់អាទិភាព

- បេក្ខជន ត្រូវសរសេរបំពេញបែបបទសុំប្រឡង ចុះហត្ថលេខា និងមកដាក់ពាក្យដោយ ផ្ទាល់ខ្លួន

- បេក្ខជន ត្រូវធ្វើលិខិតបញ្ជាក់ពីសុខភាពនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ករណីជនពិការ) និងលិខិតថ្កោលទោសនៅក្រសួងយុត្តិធម៌ ជាបន្ទាន់ក្រោយពីបានប្រឡងជាប់វិញ្ញាសាសរសេរ

- ព័ត៌មានលម្អិត សូមទំនាក់ទំនងនៅនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក (ការិយាល័យបុគ្គលិក) រៀងរាល់ម៉ោងធ្វើការ ។

អាស្រ័យហេតុនេះ សូមសិស្ស-និស្សិត និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន ។

រដ្ឋមន្ត្រី

បណ្ឌិត អ៊ុក រ៉ាប៊ុន

កន្លែងទទួល ÷

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់អង្គភាពចំណុះក្រសួងអភិវឌ្ឍន៍ជនបទ
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ